**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ៥១៦
ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២
សាលក្រមលេខ ០២១/២២"ធ"
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈ
នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៥១៦ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

**ដោយមានសមាសភាព**

**ចៅក្រម ជំនុំជម្រះ**

**លោក** [redacted] **ជាចៅក្រមសាលាដំបូងខេត្តកណ្ដាល**

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

រវាងដើមចោទ ៖

ឈ្មោះ [redacted] សុភីម ភេទស្រី កើតថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៨៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរនៅផ្ទះ មានទីលំនៅបច្ចុប្បន្ននៅ[redacted]។

មេធាវីតំណាងដោយអាណត្តិលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីនៃក្រុមហ៊ុនមេធាវីនរសិង្ហ [redacted] និងជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

និងចុងចម្លើយ៖

ឈ្មោះ [redacted] ឧសភា ភេទប្រុស កើតថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៨៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុន មានទីលំនៅបច្ចុប្បន្ននៅ[redacted]។

**អង្គហេតុ និងការអះអាងរបស់គូភាគី**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖**

១.សុំលែងលះពីប្ដីឈ្មោះ [redacted] ឧសភា ភេទប្រុស កើតថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៨៣។

២.ប្រាក់ប្រដាប់ក្ដីផ្សេងៗជាបន្ទុករបស់ចុងចម្លើយ។

**ខ. អង្គហេតុ និង ចំណុចវិវាទ**

ខ.ក.១ រឿងក្ដីនេះ **ដើមចោទ ឈ្មោះ** [redacted] សុភីម បានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្លួននិងប្ដីរបស់ខ្លួនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកាលពីអំឡុងឆ្នាំ២០១៧ និងបានចុះសំបុត្រអាពាហពិពាហ៍តាមច្បាប់កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ហើយខ្លួន និងប្ដីរបស់ខ្លួនពុំមានកូន និងទ្រព្យសម្បត្តិរួមនោះទេ ចំណែកបំណុលរួមក៏ពុំមាននោះដែរ។ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួចរាល់ហើយខ្លួន និងប្ដីរបស់ខ្លួនបានរស់នៅជាមួយគ្នាបានតែរយៈពេលតែ ៣សប្ដាហ៍តែប៉ុណ្ណោះ ចាប់តាំងពីពេលនោះមកប្ដីរបស់ខ្លួនបានទៅរស់នៅសហរដ្ឋអាមេរិកដើម្បីធ្វើការ ហើយចាប់តាំងពីពេលនោះមកគាត់ពុំដែលមកស្រុកកំណើតវិញនោះទេ។ មូលហេតុដែលខ្លួនសុំលែងលះពីប្ដីរបស់ខ្លួនគឺដោយសារតែប្ដីរបស់ខ្លួនបានចុះចោលខ្លួនអស់រយៈពេល

៥ ឆ្នាំ មកហើយដែលធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាតទៅទៀតដែរ។ ដូច្នេះខ្លួនសូមសំណូមពរដល់តុលាការមេត្តាជួយរំលាយចំណងអាពាហ៍ពិពាហ៍របស់ពួកខ្លួនទាំងពីរដោយក្តីអនុគ្រោះ។

ខ.ក.២. រឿងក្តីនេះ ចុងចម្លើយ ឈ្មោះ [redacted] ឧសភា បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ចុងចម្លើយបានទទួលដីកាកោះត្រឹមត្រូវ ប៉ុន្តែ អវត្តមាន។

**ខ.ខ អង្គហេតុដែលគ្មានវិវាទ**

ដើមចោទឈ្មោះ [redacted] សុភឹម និងចុងចម្លើយឈ្មោះ [redacted] ឧសភា បានរៀបអាពាហ៍ពិពាហ៍ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់តាមរយៈសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០២/២០១៧ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្វាយរលំ និងពុំមានកូននោះឡើយ។

**ខ.គ.ចំណុចវិវាទ**

- តើដើមចោទឈ្មោះ [redacted] សុភឹម មានមូលហេតុត្រឹមត្រូវក្នុងការលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ឧសភា ដែរឬទេ ?

**គ.ការពិនិត្យភស្តុតាង**

-សំបុត្រអាពាហ៍ពិពាហ៍លេខ ៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០២/២០១៧ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] សុភឹម និងឈ្មោះ [redacted] ឧសភា ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល។ (ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៣៤៥៧៥៦(០១) របស់ឈ្មោះ [redacted] សុភឹម ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦។(ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២១២០២៧១១ របស់ឈ្មោះ [redacted] ឧសភា ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦។ (ថតចម្លង)

-USB ចំនួន ០១។

## សំអាងហេតុ

១. យោងតាមឯកសារចម្លងនៃសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ០២/២០១៧ រវាងដើមចោទឈ្មោះ [redacted] សុភឹម និងចុងចម្លើយឈ្មោះ [redacted] ឧសភា អាចបញ្ជាក់បានថាដើមចោទ និងចុងចម្លើយជាសហព័ទ្ធនឹងគ្នាតាមផ្លូវច្បាប់ ។

២.តាមការអះអាងរបស់ដើមចោទឃើញថា បន្ទាប់ពីបានចុះសំបុត្រអាពាហ៍ពិពាហ៍ដើមចោទ និង ចុងចម្លើយ មិនបានរួមរស់ជាមួយគ្នាក្នុងនាមជាប្តីប្រពន្ធនោះឡើយ ព្រោះថាចុងចម្លើយបានទៅរស់នៅក្រៅប្រទេសចាប់តាំងពីរៀបអាពាហ៍ពិពាហ៍បានតែ៣សប្តាហ៍មកម្លេះ។ រហូតមកដល់ពេលនេះដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាអស់រយៈពេលជិត ៥ ឆ្នាំមកហើយ ប៉ុន្តែនៅតែមិនបានរួមរស់ជាមួយគ្នានោះទេ ដែលជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាជាមួយ នឹងចុងចម្លើយតទៅទៀតហើយ ដូចនេះតុលាការ យល់ឃើញថា ការលែងលះជាជម្រើសដ៏ល្អសម្រាប់ភាគីទាំងសងខាងស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ។

៣.ផ្អែកតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ។



Scanned with CamScanner

**សេចក្តីសម្រេចបញ្ចប់**

១. ឱ្យដើមចោទឈ្មោះ [redacted] សុភីម និងចុងចម្លើយឈ្មោះ [redacted] ឧសភា ដែលមានសំបុត្រអាពាហ៍ពិពាហ៍ លេខ ៤៩ សៀវភៅអាពាហ៍ពិពាហ៍លេខ ០២/២០១៧ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ចេញដោយ មន្ត្រីអត្រានុកូលដ្ឋានឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល លែងលះគ្នា ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

សាលក្រមនេះ ប្រកាសជាសាធារណៈនៅ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ។

*ភាគីមានប្តឹងទាស់ ឬឧទ្ធរណ៍នឹងសាលក្រមនេះតាមការកំណត់របស់ច្បាប់។*

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

*បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។*

ថ្ងៃច័ន្ទ ០៨ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល, ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

ក្រឡាបញ្ជីលោកស្រី [redacted] (ជ.ប)